## សុន្ទរកថានៅឯពិធីលៀងសាយតោជន៍ បន្ទាប់ពីការស្បថចូលកាន់តំណែងរបស់មន្ត្រីតុលាការជាតិ និងអន្តរជាតិ សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ដោយឯកឧត្តម សុខ អាន**
**ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាល**

**ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៦**
**សណ្ឋាគារ Raffles Hotel Le Royal រាជធានីភ្នំពេញ**

ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងជាពិសេសបំផុតគឺលោក-លោកស្រីចៅក្រម និងលោក-លោកស្រីព្រះរាជអាជ្ញានៃ អវតក ដែលបានស្បថចូលកាន់តំណែងថ្មីៗ ជាទីមេត្រី!

យើងជួបជុំគ្នានាល្ងាចនេះ ដើម្បីអបអរសាទរនូវពិធីជាប្រវត្តិសាស្ត្រនាថ្ងៃនេះ ដែលមន្ត្រីតុលាការជាតិ និងអន្តរជាតិនៃ អវតក បានស្បថចូលកាន់តំណែងនៅចំពោះមុខរូបសំណាកអតីតព្រះមហាក្សត្រព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម (ព្រះសុវណ្ណកោដិ) នៅក្នុងព្រះបរមរាជវាំង ដែលដឹកនាំពិធីដោយរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ឯកឧត្តម Nicholas Michel អគ្គលេខាធិការរង និងជាមន្ត្រីច្បាប់ ដែលខ្ញុំសូមសម្តែងការស្វាគមន៍ចំពោះទស្សនកិច្ច(ផ្លូវការ?)លើកដំបូងរបស់ឯកឧត្តម មកកាន់ព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីពិធីនៅថ្ងៃនេះ ទីបំផុត យើងអាចចាប់ផ្តើមដំណើរការផ្លូវតុលាការ ក្នុងការនាំយកចារីមកកាត់ទោសពីឧក្រិដ្ឋកម្មនានាដែលហួសពីការស្រមៃរបស់មនុស្សជាតិ តែជាអកុសលវាបានកើតឡើងនៅទីនេះ នៅក្នុង


Original EN: 01699286-01699287

ប្រទេសដែលបានបង្កើតភាពស្រស់ស្អាតនៃព្រះបរមរាជវាំង និងពិធីវប្បធម៌ និងសាសនាដែលឯកឧត្តម លោកជំទាវ លោក-លោកស្រី បានឃើញនៅថ្ងៃនេះ។

ខ្ញុំសូមស្វាគមន៍មន្ត្រីតុលាការទាំង ២៧ រូបមកពីប្រទេសចំនួនដប់ ហើយខ្ញុំសូមផ្តល់ការគាំទ្រយ៉ាងពេញទំហឹងចំពោះរាជរដ្ឋាភិបាលកម្ពុជា ចំពោះកិច្ចការយ៉ាងធំធេងដែលនៅចំពោះមុខលោក-លោកស្រី។ យើងយល់ថា នៅថ្ងៃស្អែក លោក-លោកស្រីនឹងជួបពិភាក្សារួមគ្នា នៅក្នុងសិក្ខាសាលាបង្កើត និងរៀបចំផែនការយុទ្ធសាស្ត្រផ្លូវតុលាការ ដែលមានរយៈពេលបួនថ្ងៃ ដើម្បីបង្កើតក្រុមការងារដែលនឹងបំពេញការងារជាមួយគ្នា ក្នុងរយៈពេលប៉ុន្មានឆ្នាំទៅមុខ។ ខ្ញុំមានជំនឿថា លោក-លោកស្រីនឹងរៀបចំផែនការដើម្បីពិភាក្សាអំពីយន្តការនៃកិច្ចសហប្រតិបត្តិការ និងការរៀបចំការងារ ហើយនឹងចាប់ផ្តើមដំណើរការពិនិត្យថាតើ នីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជាត្រូវបានបំពេញបន្ថែមឬទេ ហើយនៅពេលណា និងតាមរបៀបណា ដូចមានចែងនៅក្នុងច្បាប់ និងកិច្ចព្រមព្រៀង។ ខ្ញុំសូមជូនពរលោក-លោកស្រីទទួលបានជោគជ័យក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ ដោយដឹងថា យើងចាំបាច់ត្រូវមានមូលដ្ឋានគ្រឹះសម្រាប់ស្ថាបនាស្ថាប័នដ៏ធំមួយ។

ក្រុមដំបូងផ្នែកការិយាល័យរដ្ឋបាល ដែលបានចាប់ផ្តើមការងាររបស់ខ្លួនតាំងពីថ្ងៃទី០៦ ខែកុម្ភៈ មកនេះ នាពេលនេះកំពុងឈានដល់សប្តាហ៍បញ្ចប់ការងាររបស់ខ្លួនហើយ។ ខ្ញុំសូមអបអរសាទរចំពោះប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកទាំងអស់ ទាំងខាងភាគីជាតិ និងភាគីអន្តរជាតិ ចំពោះសមិទ្ធិផលដែលសម្រេចបាន ក្នុងការរៀបចំចាប់ផ្តើមការងារតុលាការ។ បើតាមគម្រោង ឆ្នាំដំបូងនៃដំណើរការរបស់ អវតក នឹងចាប់ផ្តើមនៅពេលសហព្រះរាជអាជ្ញាចាប់ផ្តើមការងាររបស់ខ្លួន ដែលនៅពេលនេះ គឺគ្រោងចាប់ផ្តើមនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ ក្នុងរយៈពេលមួយសប្តាហ៍ទៀត។

ខ្ញុំគិតថា រាត្រីនេះជាពេលវេលាដែលសក្តិសមក្នុងការផ្អាកបន្តិច និងសម្លឹងមើលគោលបំណងនានានៃការបង្កើត អវតក។ គោលបំណងចម្បងរបស់យើងគឺផ្តល់យុត្តិធម៌ជូនជនរងគ្រោះ និងសម្រាប់ប្រជាជនកម្ពុជាទាំងមូល។ ក្នុងការសម្រេចឲ្យបានយុត្តិធម៌ដែលរង់ចាំជាយូរមកនេះ យើងមិនត្រូវធ្វើឲ្យប៉ះពាល់ដល់សន្តិភាពជាតិ និងស្ថិរភាពរបស់ប្រទេសដែលយើងទើបតែទទួលបាននាពេលថ្មីៗនេះទេ។



Original EN: 01699286-01699287

យើងសង្ឃឹមថា ប្រជាពលរដ្ឋរបស់យើងនឹងតាមដានការងាររបស់ អវតក ហើយតាមរយៈនេះក្មេងជំនាន់ក្រោយអាចយល់ដឹងបានពីអ្វីដែលឪពុកម្តាយពួកគេបានឆ្លងកាត់ ហើយពួកគេប្តេជ្ញានឹងធានាថា ឧក្រិដ្ឋកម្មទាំងនេះនឹងមិនកើតមានជាថ្មីនៅទីនេះ ឬនៅទីកន្លែងផ្សេងទៀតក្នុងពិភពលោកនេះឡើយ។ ដូចដែលនៅពេលនេះប្រជាជនកម្ពុជាកំពុងចែករំលែកចំណេះដឹង និងភាពជំនាញរបស់ខ្លួន ដើម្បីជួយដល់ប្រជាជនស៊ូដង់ ក្នុងការលប់បំបាត់ទុក្ខវេទនាដោយសារគ្រាប់មីន ហេតុនេះយើងសង្ឃឹមថា ការងាររបស់មន្ត្រីតុលាការកម្ពុជា និងមន្ត្រីតុលាការអន្តរជាតិក៏នឹងជួយបញ្ចប់នូវទុក្ខវេទនានៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដែរ។

យើងមានក្តីសង្ឃឹមយ៉ាងមុតមាំ និងរំពឹងថា អវតក នឹងជាតុលាការគំរូសម្រាប់ប្រទេសកម្ពុជា ហើយយើងក៏គិតផងដែរថា ប្រសិនបើយើងទទួលជោគជ័យចំពោះកាតព្វកិច្ចដែលនៅចំពោះមុខយើងបាន គំរូតុលាការនៅកម្ពុជានេះអាចក្លាយជាការជំរុញចិត្តចំពោះអ្នកដែលមានបំណងប្រាថ្នាចង់បង្កើតតុលាការកូនកាត់ផ្សេងទៀត។

សម្រាប់ឯកឧត្តម លោកជំទាវ លោក-លោកស្រីទាំងអស់ដែលបានចូលរួម ពិធីនៅថ្ងៃនេះតំណាងឲ្យការពូនផ្តុំក្តីសង្ឃឹម និងសុបិន្តជាច្រើនឆ្នាំមកនេះ ដែលយើងអាចសម្រេចបានដោយសារការខិតខំប្រឹងប្រែង និងការតាំងចិត្តខ្ពស់។ ខ្ញុំសូមសម្តែងនូវការគោរពចំពោះអ្នកទាំងឡាយដែលមានជំនឿជាក់ថា យើងអាចទទួលបានយុត្តិធម៌ ទោះបីជាច្រើនឆ្នាំបានកន្លងផុតទៅក្តី ដែលពួកគេភាគច្រើនក៏មានវត្តមានជាមួយយើងនៅរាត្រីនេះដែរ។

-- ចប់ --